អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១០

# សេចក្តីប្រកាស
## ស្តីអំពី
## រង្វាន់សម្រាប់"ការប្រើប្រាស់បច្ចេកវិទ្យាថ្មីសន្លាងបំផុតនៅអំឡុងពេលសវនាការ" របស់ អ វ ត ក

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានទទួលរង្វាន់"ប្រើប្រាស់បច្ចេកវិទ្យាថ្មីសន្លាងបំផុតនៅអំឡុងពេលសវនាការ" នៅក្នុងកម្មវិធីរង្វាន់របស់**ទស្សនាវដ្តី បច្ចេកវិទ្យាព័ត៌មាន Law Technology News Awards** ប្រចាំឆ្នាំលើកទី៧ នៅសហរដ្ឋអាមេរិក។ សូមមើលរូបភាពដែលបានភ្ជាប់មកជាមួយ ឬចូលគេហទំព័រខាងក្រោម:
http://www.law.com/jsp/lawtechnologynews/PubArticleLTN.jsp?id=1202436467199

ទស្សនាវដ្តីបច្ចេកវិទ្យាព័ត៌មានរបស់សហរដ្ឋអាមេរិកគឺជាគ្រឹះស្ថានបោះពុម្ពផ្សាយប្រចាំខែដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក ដែលផ្តោតទៅ លើបច្ចេកវិទ្យា ផលិតផល និង សេវាកម្មថ្មីៗបំផុតសម្រាប់ទីផ្សារ ផ្នែកច្បាប់។ ទស្សនាវដ្តីនេះបានសម្រេចជ្រើសរើសអង្គជំនុំជម្រះវិសាមញ្ញ (អ វ ត ក) ជាជ័យលាភីរង្វាន់ដោយសារ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "សម្រេចបាននូវជោគជ័យក្នុងការដំឡើង និង ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានទោះបីជាមាន ការលំបាកលំបិន ការខ្វះខាតថវិកា និង ថវិកាមានកម្រិតយ៉ាងណាក៏ដោយ" នៅក្នុងរយៈពេលនៃសវនាការរឿងក្តីដំបូងប្រឆាំងនឹងអតីត ប្រធានគុកម្នាក់ឈ្មោះ កាំង ហ្កេក អ៊ាវ ហៅឌុច។

នៅក្នុងអំឡុងពេលសវនាការចំនួន ៨ ខែ ដែលបានបញ្ចប់ទៅនៅចុងខែ វិច្ឆិកា ឆ្នាំ២០១០ គឺមានសាក្សីចំនួន៥៥នាក់ ក្នុងនោះរួមមាន ជនរងគ្រោះ និង អតីតកងការពារ ព្រមទាំងអ្នកស្នួរចម្លើយ ដែលបានផ្តល់សក្ខីកម្មអំពីបទពិសោធន៍ដ៏គួរឲ្យរន្ធត់ដែលខ្លួនបានជួបប្រទះ ហើយ មានអ្នកទស្សនាចំនួន ៣១.០០០ នាក់ បានទស្សនាដំណើរការនីតិវិធីយ៉ាងយកចិត្តទុកដាក់នៅក្នុងសាលសវនាការសាធារណៈ ។

ទស្សនាវដ្តីបច្ចេកវិទ្យាព័ត៌មាន **Law Technology News Awards** បាននិយាយថា នៅខាងក្រោយសាលសវនាការ បុគ្គលិកផ្នែកបច្ចេកទេសព័ត៌មានវិទ្យាទាំងជាតិនិងអន្តរជាតិនៃ អ វ ត ក បានធ្វើការយ៉ាងសស្រាក់សស្រាំដោយមិនខ្លាចនឿយហត់ដើម្បីធានាឲ្យប្រាកដថា កិច្ចការសវនាការប្រព្រឹត្តទៅដោយរលូន។ បុគ្គលិកទាំងនោះបានផ្តល់នូវសេវា បកប្រែប្រដេញជា ៣ ភាសាដែលជាភាសាផ្លូវការរបស់តុលាការ បានផ្តល់នូវរូបភាពវីដេអូតាមរយៈបណ្តាញភ្ជាប់សម្រាប់ទទួលចម្លើយ កសិណសាក្សីពីបរទេស ព្រមទាំងបានផ្តល់បណ្តាញផ្សាយបន្តផ្ទាល់សម្រាប់ទូរទស្សន៍ទៀតផង។ នេះមិនទាំងរាប់អំពីការផ្តល់នូវសេវាកម្ម ឬកិច្ចការផ្សេងៗទៀតឡើយ។

រង្វាន់នេះ គឺជាសក្ខីភាព សបញ្ជាក់អំពីការតាំងចិត្តរបស់បុគ្គលិកសាលាក្តី ដែលបានខិតខំធ្វើការទាំងយប់ទាំងថ្ងៃ ដើម្បីធ្វើឲ្យកិច្ចសវនាការនេះទទួលបានជោគជ័យ។

ចំពោះព័ត៌មានបន្ថែម សូមទាក់ទង៖

លោក **រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 156

លោក **ឌីម សុវណ្ណារុំ**
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855(0) 12 488094

ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិក reach.sambath@eccc.gov.kh

ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិក dim.sovannarom@eccc.gov.kh

លោក **ឡាស អូលសិន**
មន្ត្រីច្បាប់ទទួលផ្នែកទំនាក់ទំនង
ទូរស័ព្ទចល័តលេខ +855(0) 12 488 023
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6169
សារអេឡិចត្រូនិច olsenl@un.org

លោកស្រី**យូកូមេដា**
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 319
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6139
សារអេឡិចត្រូនិក maeday@un.org